ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ករណីឧបទ្ទវហេតុអគ្គិភ័យ នៅរោងចក្រស្បែកជើង អ.ជី ហ្វ៊ុតវែរ (ខេមបូឌា) ឯ.ក
## (R.G FOOTWEAR (CAMBODIA) CO ., LTD.)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិត និងសាធារណជនឱ្យបានជ្រាបថា នៅថ្ងៃចន្ទ ទី១៨ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ១៦:៥០នាទីរសៀល មានករណីអគ្គិភ័យឆាបឆេះអគាររោងចក្រស្បែកជើង អ.ជី ហ្វ៊ុតវែរ (ខេមបូឌា) ឯ.ក (R.G Footwear (Cambodia) CO ., LTD.) ដែលស្ថិតនៅភូមិអណ្តូង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានកម្មករនិយោជិតធ្វើការចំនួន ២ ២០៥នាក់ (ស្រី ១ ០៣៦នាក់)។ បន្ទាប់ពីទទួលព័ត៌មានភ្លាម ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះទៅដល់កន្លែងកើតហេតុ និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធប្រកបដោយការយកចិត្តទុកដាក់បំផុត។ សមត្ថកិច្ចកំពុងបន្តស៊ើបអង្កេតរកមូលហេតុដែលបង្កឱ្យមានអគ្គិភ័យ រីឯកម្មករនិយោជិតពុំមានរងគ្រោះថ្នាក់ណាមួយទេ។

នៅព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ នេះ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រសួង បន្តចុះពិនិត្យ និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ថៅកែ រដ្ឋបាលរោងចក្រ និងតំណាងកម្មករនិយោជិត ដើម្បីការពារអត្ថប្រយោជន៍ផ្សេងៗរបស់បងប្អូនកម្មករនិយោជិត។ ជាមួយគ្នានេះ ក្រសួងសូមសម្តែងនូវសេចក្តីសោកស្តាយបំផុតចំពោះឧបទ្ទវហេតុអគ្គិភ័យនេះ និងសូមថ្លែងអំណរគុណដល់អាជ្ញាធរមានសមត្ថកិច្ច កម្លាំងពន្លត់អគ្គិភ័យ ព្រមទាំងថ្នាក់ដឹកជាច្រើនរូបដែលបានចុះអន្តរាគមន៍នៅទីតាំងកើតហេតុយ៉ាងសកម្ម និងប្រកបដោយការយកចិត្តទុកដាក់បំផុតដើម្បីពន្លត់និងគ្រប់គ្រងស្ថានភាពអគ្គិភ័យ មិនឱ្យរាលដាលដល់រោងចក្រ និងកន្លែងផ្សេងទៀត។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់បងប្អូនកម្មករនិយោជិតនៃរោងចក្រស្បែកជើង អ.ជី ហ្វ៊ុតវែរ ដែលអាចប្រឈមនឹងបញ្ហាមួយចំនួន។ ដើម្បីជួយសម្រាលទុក្ខលំបាករបស់បងប្អូនកម្មករនិយោជិត ក្រសួងសូមបញ្ជាក់ថា សម្រាប់អត្ថប្រយោជន៍ ប.ស.ស. រួមមាន ផ្នែកថែទាំសុខភាព អត្ថប្រយោជន៍នៅពេលសម្រាលកូន និងការពិនិត្យផ្ទៃពោះ បងប្អូនកម្មករនិយោជិតនៅតែទទួលបានអត្ថប្រយោជន៍ និងប្រើប្រាស់ ប.ស.ស. ជាធម្មតា។

ក្នុងករណីបងប្អូនកម្មករនិយោជិតចង់ស្វែងរកការងារ បងប្អូនកម្មករនិយោជិតក៏អាចចាប់យកឱកាសការងារថ្មីតាមរយៈមជ្ឈមណ្ឌលការងារចល័ត នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA)។ ក្រសួងនឹងចុះ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

ផ្សព្វផ្សាយពីឱកាសការងារ និងមានមន្ត្រីវង់ចាំចុះឈ្មោះស្វែងរកការងារធ្វើភ្លាមៗជូនបងប្អូនកម្មករនិយោជិត នៅម៉ុរោងចក្រស្បែកជើង អ.ជី ហ្វ៊ុតវែរ ដើម្បីឱ្យបងប្អូនទទួលបានឱកាសការងារថ្មីជាមួយនឹងរោងចក្រ សហគ្រាស ដែលនៅក្បែរនឹងតំបន់ដែលបងប្អូនរស់នៅស្រាប់ ឬទាក់ទងមក Hotline ១២៨៦ និង ១២៩៧ ឬទាក់ទងមក លេខទូរស័ព្ទ ០៧៧ ២៣២ ៣៧៨ ឬ ០១៦ ៧៨៦ ៦៥៥ (Telegram)។

អាស្រ័យហេតុនេះ សូមបងប្អូនកម្មករនិយោជិត និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤